


# ដំបូន្មានព្រះពុទ្ធ
# ៥០០០ឆ្នាំ


រៀបរៀងដោយ

ភិក្ខុ **នឿន ឈិនឡុង**

វត្តសាវារាម (វត្តស្រះចក) ខេត្តព្រះវិហារ


ដំបូន្មានព្រះពុទ្ធ ៥០០០ឆ្នាំ
រៀបរៀងដោយ ភិក្ខុសិរីសាក្យមុនីបុត្តោ នឿន ឈិនឡុង

# ជំបូន្មានព្រះពុទ្ធ ៥០០០ឆ្នាំ

*រៀបរៀងដោយៈ*

## ព្រះគ្រូសិរីវិសុទ្ធិញាណ ងៀន ឈិនឡុង

*ព.ស. ២៥៦៨* *គ.ស. ២០២៤*

ផ្សាយចេញពី **វត្តសារារាម** (វត្តស្រះចក)

ស្ថិតនៅភូមិកំពត ឃុំរហ័ស ស្រុករវៀង ខេត្តព្រះវិហារ

បោះពុម្ពលើកទី១ ចំនួន ១,០០០ ក្បាល

# អារម្ភកថា

ដោយជ្រះថ្លាចំពោះព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធសុទ្ធតែជាពាក្យពីរោះៗ សម្រាប់អប់រំដាស់តឿន សត្វលោក ។ ព្រះធម៌ជាប្រទីបបំភ្លឺសត្វលោកឱ្យឃើញការពិតក្នុងលោក អ្វីជាបុណ្យកុសល អ្វីជាបាបអកុសល ដែលព្រះពុទ្ធទ្រង់បានសម្តែងដល់ពុទ្ធបរិស័ទសម្រាប់យកទៅបដិបត្តិដើម្បីឱ្យបានរួចចាកទុក្ខទាំងពួង ៕

# ថ្លែងអំណរគុណ

សូមអរព្រះគុណចំពោះ គណៈកម្មការដែលបានជួយពិនិត្យអក្ខរាវិរុទ្ធ និង សប្បុរសជនទាំងឡាយ ដែលបានជួយឧបត្ថម្ភ សូមប្រគេនពរ និង ជូនពរទទួលបាននូវពុទ្ធពរ ៤ ប្រការ គឺៈ

អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

# គណៈកម្មការត្រួតពិនិត្យ

ព្រះគ្រូសិរីវិសុទ្ធិញាណ នឿន ឈិនឡុង

ព្រះមហា ផេង ភារម្យ *សមណនិស្សិត*

ព្រះមហា ព្រហ្ម ហ៊ីន *សមណនិស្សិត*

ព្រះមហា នៅ រត្ថនា *សមណនិស្សិត*

ធម្មទានឈ្នះអាមិសទានទាំងពួង

ធម្មរសឈ្នះរសទាំងពួង

សេចក្តីត្រេកអរក្នុងធម៌

ឈ្នះសេចក្តីត្រេកអរទាំងពួង

ការអស់តណ្ហាឈ្នះទុក្ខទាំងពួង ។

*ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្ដីសុខ*

*ការសម្ដែងនូវព្រះសទ្ធម្ម នាំមកនូវសេចក្ដីសុខ*

*សេចក្ដីព្រមព្រៀងគ្នានៃសង្ឃ ឬ ពួកក្រុម នាំមកនូវសេចក្ដីសុខ*

*សេចក្ដីព្យាយាមដុតកិលេស នៃអ្នកព្រមព្រៀងគ្នាទាំងនោះ*

*នាំមកនូវសេចក្ដីសុខ ។*

*ធម៌ទាំងឡាយមានចិត្តជាធំ មានចិត្តប្រសើរបំផុត សម្រេចមកពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសៈប្រទូសរ៉ាយហើយ ទោះនិយាយក្តី ធ្វើក្តី (ក៏អាក្រក់ដែរ), ព្រោះអំពើអាក្រក់នោះឯងហើយ សេចក្តីទុក្ខរមែងដេញជាប់តាមក្រោយបុគ្គលនោះ ដូចជាកង់រទេះវិល តាមស្នាមជើងគោដែលអូសនឹមរទេះ យ៉ាងដូច្នោះឯង ។*

*ធម៌ទាំងឡាយមានចិត្តជាធំ មានចិត្តប្រសើរបំផុត សម្រេចមកពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ទោះនិយាយក្តី ធ្វើក្តី (ក៏ល្អទាំងអស់), ព្រោះចិត្តជ្រះថ្លានោះឯង សេចក្តីសុខរមែងតាមជាប់បុគ្គលនោះដូចស្រមោលដែលអន្ទោលតាមប្រាណ យ៉ាងដូច្នោះឯង ។*

***កិរិយាមិនធ្វើអំពើបាប ១***

***កិរិយាធ្វើតែអំពើល្អ ១***

***កិរិយាជម្រះចិត្តឱ្យស្អាត ១***

***ទាំងនេះជាពាក្យទូន្មាននៃព្រះពុទ្ធទាំងឡាយ ។***

***បុគ្គលប្រៀនប្រដៅអ្នកដទៃយ៉ាង***

***ត្រូវធ្វើខ្លួនឱ្យបានយ៉ាងនោះដែរ***

***អ្នកដែលទូន្មានខ្លួនល្អហើយ***

***គួរនឹងទូន្មានអ្នកដទៃបាន ព្រោះថា***

***ខ្លួនគឺបុគ្គលទូន្មានដោយកម្រពេកណាស់ ។***

*ពពក មិនអាចបិទបាំងព្រះចន្ទ*

*និង ព្រះអាទិត្យ បានយូរអង្វែង*

*ឬ រឿងរហូត យ៉ាងណាមិញ*

*ការពិតក្នុងលោកនេះក៏មិនអាច*

*លាក់បាំងបាន យ៉ាងនោះដែរ ។*

*មនុស្សទាំងឡាយច្រើននាក់*

*ត្រូវភ័យគំរាមហើយ តែងយកភ្នំ ព្រៃ និងអារាម*

*រុក្ខចេតិយជាទីពឹង ទីពឹងបែបនេះមិនមែនជាទីពឹងដ៏ឧត្តមទេ*

*បុគ្គលអាស្រ័យទីពឹងបែបនេះ មិនដែលរួចស្រឡះ*

*ចាកទុក្ខទាំងពួងបានឡើយ ។*

***បុគ្គលមិនមែន ជាអ្នកថោកទាប***

***ព្រោះជាតិទេ មិនមែនជាអ្នកប្រសើរថ្លៃថ្នូរ***

***ព្រោះជាតិទេ បុគ្គលជាអ្នកថោកទាប ឬ ថ្លៃថ្នូរ***

***ក៏ព្រោះតែកម្ម (អំពើ) ។***

***ធ្វើបាបដោយខ្លួនឯង***

***រមែងសៅហ្មងដល់ខ្លួនឯងវិញ***

***បើមិនធ្វើបាបដោយខ្លួនឯងហើយ***

***តែងបរិសុទ្ធស្អាតដល់ខ្លួនឯង សេចក្តីបរិសុទ្ធ***

***និងមិនបរិសុទ្ធ តែងកើតមានចំពោះខ្លួនឯង ។***

*មនុស្សខ្លះ មានភ្នែកដូចជាភ្នែកខ្វាក់*

*មានត្រចៀកដូចជាត្រចៀកថ្លង់*

*មានបញ្ញាដូចជាមនុស្សគ មានកម្លាំងដូចជាមនុស្សខ្សោយ*

*កាលបើប្រយោជន៍មកដល់ព្រមហើយខ្លួនឯងទៅដេក*

*ដូចជាមនុស្សស្លាប់ទៅវិញ ។*

*អ្នកឯណាឃើញភរិយាអ្នកដទៃ*

*តាំងចិត្តស្មើដូចឃើញម្តាយបង្កើត*

*ឃើញសម្បត្តិអ្នកដទៃ ក៏តាំងចិត្តស្មើដូចឃើញដុំដី*

*ឃើញសត្វទាំងពួងតាំងចិត្តស្មើដូចខ្លួន*

*អ្នកនោះជា បណ្ឌិត ពិតមែន ។*

# ហេតុដែលកើតប្រាជ្ញា មាន ៨ យ៉ាងគឺ

មនុស្សមានវ័យល្អ ១ មានយសបរិវារ ១ ខំសាកសួរ ១ មិនសេពគប់

នូវអន្យតិរ្ថិយ ១ មានចិត្តជាឧបាយ ១ និយាយតែអំពីអត្ថ

និងធម៌ ១ មានចិត្តស្នេហាក្នុងធម៌អាថ៌ ១

នៅក្នុងប្រទេសដ៏សមគួរ ១ ។

# មនុស្សពាល

បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ

ស្ងួម្បីរស់ ១ ជីវិតក្តី   ក៏ឥតបានដឹងធម៌អាថ៌អ្វី

ឱ្យច្បាស់លាស់ឡើយ ដូចគ្នា

នឹងវែកដែលមិនដឹងនូវរសសម្ល ។

# វិញ្ញូជន

បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ

សូម្បីតែមួយរំពេច រមែងយល់រសធម៌

ដោយឆាប់រហ័ស ដូចជាអណ្តាតដឹងនូវរសសម្ល ។

*បុគ្គលណារស់នៅ ១០០ ឆ្នាំ*

*ជាមនុស្សមិនមានប្រាជ្ញា មានចិត្តមិនតម្កល់ខ្ជាប់*

*ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានប្រាជ្ញា*

*មានការពិនិត្យពិចារណាជាប្រក្រតីប្រសើរជាង ។*

*ពួកហង្ស តែងហើរទៅក្នុងគន្លងផ្លូវព្រះអាទិត្យ*

*អ្នកមានឫទ្ធិ តែងហោះទៅក្នុងអាកាសដោយឫទ្ធិ*

*អ្នកប្រាជ្ញ ផ្ចាញ់កិលេសមារ ព្រមទាំងវាហនៈ*

*គឺតណ្ហាបានហើយ រមែងរលាស់ខ្លួនចេញចាកលោកបាន ។*

***មនុស្សទុរជន គឺជនមានចិត្តអាក្រក់***

***បើទុកជាប្រដាប់ហើយដោយវិជ្ជា ក៏គួរអ្នកទាំងឡាយ***

***គប្បីវៀងដោយពិត  ដូចជាសត្វមានអាសិរពិស***

***បើទុកជាប្រដាប់ហើយដោយកែវមណី ដូចម្ដេច***

***ក៏វាគង់នឹងធ្វើឱ្យភ័យកើតឡើងបាន ។***

***ដរាបណា បាបមិនទាន់ឱ្យផល***

***បុគ្គលពាលសម្គាល់ថា បាបមានរសជាតិផ្អែមដូចទឹកឃ្មុំ***

***ដល់ពេលបាបឱ្យផល បុគ្គលពាលបានដល់នូវសេចក្តីទុក្ខ ។***

*ផ្លែល្វាដែលទុំហើយ*

*ខាងក្រៅមានពណ៌ក្រហមស្រស់*

*តែខាងក្នុងពេញដោយសត្វមមង់ ដូចម្តេចមិញ*

*រីធម្មតារបស់មនុស្សមានចិត្តអាក្រក់ក៏ដូច្នោះឯង ។*

បុគ្គលគប្បីឈ្នះមនុស្សក្រោធខឹង    ដោយការមិនខឹងក្រោធ

បុគ្គលគប្បីឈ្នះមនុស្សមិនល្អ    ដោយសេចក្តីល្អ

បុគ្គលគប្បីឈ្នះមនុស្សកំណាញ់    ដោយការឱ្យទាន

បុគ្គលគប្បីឈ្នះមនុស្សនិយាយឡេះឡោះ   ដោយការនិយាយពាក្យពិតមានប្រយោជន៍ ។

*បុគ្គលអ្នកធ្វើបុណ្យទុក*

*រមែងរីករាយក្នុងលោកទាំងពីរគឺ រីករាយក្នុងលោកនេះ ១*

*និង លោកខាងមុខ ១ បុគ្គលនោះរមែងរីករាយស្រស់ស្រាយ*

*ព្រោះឃើញអំពើបរិសុទ្ធរបស់ខ្លួន ។*

*ផ្ទះដែលប្រក់ល្អហើយ ដំណក់ទឹកភ្លៀង*

*រមែងមិនលេចរហូត យ៉ាងណាមិញ*

*ចិត្តដែលបុគ្គលបានអប់រំទុកល្អហើយ*

*រាគៈរមែងមិនចាក់ដោតបាន យ៉ាងនោះឯង ។*

*បុគ្គលគួរប្រញាប់ប្រញាល់ធ្វើនូវអំពើល្អ*

*គប្បីហាមប្រាមចិត្តឱ្យផុតពីបាប*

*ព្រោះថា បើបុគ្គលយឺតយ៉ាវក្នុងការធ្វើបុណ្យ*

*ចិត្តរមែងត្រេកអរក្នុងបាប ។*

***បុរសដែលមានការចេះដឹងតិចតួច***

***រមែងចាស់ទៅដូចជាគោចាស់ ដែលគេឈប់ប្រើប្រាស់***

***សាច់ទាំងឡាយរបស់គេរមែងចម្រើន***

***តែបញ្ញារបស់គេមិនចម្រើនឡើយ ។***

*ផ្កាដែលមានទ្រង់ទ្រាយល្អ*

*មានពណ៌ មានក្លិន រមែងក្រអូបដល់អ្នកដែលទ្រទ្រង់*

*ដូចម្តេចមិញ វាចាសុភាសិត រមែងមានផលដល់អ្នកធ្វើ*

*តាមដោយគោរព ដូច្នោះឯង ។*

***បុគ្គលណា ដែលឈ្នះមនុស្ស ១,០០០ នាក់***

***នៅក្នុងសមរភូមិ បុគ្គលនោះមិនឈ្មោះថា***

***អ្នកឈ្នះដ៏ប្រសើរឡើយ ចំណែក ឯបុគ្គលណា***

***យកឈ្នះខ្លួនឯងតែម្នាក់បាន បុគ្គលនោះ***

***ឈ្មោះថា ឈ្នះដ៏ប្រសើរបំផុត ។***

*ខ្លួនហ្នឹងហើយជាទីពឹងរបស់ខ្លួន*

*បុគ្គលដទៃជាទីពឹងដូចម្ដេចបាន*

*ព្រោះថាបុគ្គលដែលបានអប់រំខ្លួនបានល្អហើយ*

*រមែងបាននូវទីពឹងដែលគេបានដោយកម្រ ។*

អំពើអាក្រក់

មនុស្សអាក្រក់ធ្វើបានដោយងាយ

អំពើល្អប្រពៃ

មនុស្សអាក្រក់ធ្វើបានដោយលំបាក ។

*បុគ្គលណាប្រមាទហើយកាលមុន*

*លុះក្រោយមកជាអ្នកមិនប្រមាទ*

*រមែងញុំាងនូវលោកនេះឱ្យភ្លឺស្វាង*

*ដូចជា ព្រះចន្ទចេញផុតស្រឡះពពក ដូច្នោះឯង ។*

*អ្នកឈ្នះរមែងជួបប្រទះនូវពៀរ*

*អ្នកចាញ់តែងដេកជាទុក្ខ*

*អ្នកដែលស្ងប់រម្ងាប់លះបង់នូវ*

*ការឈ្នះចាញ់បានហើយ រមែងនៅជាសុខ ។*

*បុគ្គលមិនឈ្មោះថាជាបណ្ឌិត*

*ព្រោះតែហេតុចេះនិយាយច្រើននោះទេ លុះត្រាតែ*

*ជាអ្នកដែលមាននូវសេចក្តីក្សេមក្សាន្ត មិនមាននូវពៀរ*

*ដែលមិនមានភ័យ តថាគតហៅថា បណ្ឌិត ។*

*ការគោរពបដិបត្តិល្អចំពោះ មាតាបិតា*

*នាំសេចក្តីសុខមកឱ្យក្នុងលោក*

*ការគោរពបដិបត្តិល្អចំពោះ សមណៈ*

*នាំសេចក្តីសុខមកឱ្យក្នុងលោក ។*

*សីលនាំសេចក្តីសុខមកឱ្យ ដរាបដល់ចាស់ជរា*

*សទ្ធាដែលតម្កល់ខ្ជាប់ខ្ជួនហើយ នាំសេចក្តីសុខមកឱ្យ*

*ការមានន្ទូវបញ្ញា នាំសេចក្តីសុខមកឱ្យ*

*ការមិនធ្វើន្ទូវបាប នាំសេចក្តីសុខមកឱ្យ ។*

*ទឹកភ្លៀង ធ្លាក់ចុះលើទីទួល*

*រមែងហូរទៅកាន់ទីទាប ដូចម្ដេចមិញ*

*ទានដែលបុគ្គលបានធ្វើហើយអំពីលោកនេះ*

*រមែងសម្រេចផល ដល់ប្រេតទាំងឡាយ ដូច្នោះដែរ ។*

*សេចក្តីមិនប្រមាទ គឺជាផ្លូវនៃសេចក្តីមិនស្លាប់*

*សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់*

*ជនណាដែលមិនប្រមាទហើយ ឈ្មោះថាមិនស្លាប់*

*ជនណាប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។*

***អន្លង់ទឹកជ្រៅ ថ្លាស្អាត មិនមានកករល្អក់***

***យ៉ាងណាមិញ បណ្ឌិតទាំងឡាយ***

***កាលបើបានស្តាប់នូវព្រះធម៌ទេសនាហើយ***

***រមែងជ្រះថ្លាស៊ប់សួន (មានចិត្តមិនកករល្អក់) យ៉ាងនោះដែរ ។***

*បុគ្គលមិនគួរមើលងាយបាបថា*

*មានប្រមាណតិច នឹងមិនឱ្យផលដូច្នេះឡើយ*

*ប្រៀបដូចក្អមទឹក*

*រមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះមក ។*

*បើដំបៅមិនមាននៅក្នុងបាតដៃទេ*

*បុគ្គលគប្បីនាំយកនូវថ្នាំពិសដោយបាតដៃបាន*

*ថ្នាំពិសមិនអាចចូលទៅតាមបាតដៃ*

*ដែលគ្មានដំបៅនោះបានឡើយ យ៉ាងណាមិញ*

*បាបរមែងមិនមានដល់បុគ្គលអ្នកមិនធ្វើ យ៉ាងនោះឯង ។*

*ពួកញាតិមិត្តសម្លាញ់ រមែងត្រេកអរនឹងការមកដល់*

*នៃបុរសដែលឃ្លាតគ្នាដ៏យូរអំពីចម្ងាយដោយក្តីរីករាយ*

*យ៉ាងណាមិញ បុណ្យទាំងឡាយតែងទទួលបុគ្គល*

*ដែលបានធ្វើបុណ្យទុកហើយ*

*លះលោកនេះទៅកាន់លោកខាងមុខ ។*

# អ្នកមានប្រាជ្ញា

*គួរកម្ចាត់បង់នូវមន្ទិលរបស់ខ្លួន បន្តិចម្តងៗ*

*រាល់ៗ ខណៈដោយលំដាប់ ដូចជាងមាស*

*ជម្រះនូវស្នឹមនៃមាស ដូច្នោះឯង ។*

# តថាគត

*នឹងអត់ធន់ចំពោះពាក្យសម្តី ដែលអ្នកដទៃ*

*និយាយហួសប្រមាណ ដូចជាដំរីដែលមានសេចក្តីអត់ធន់*

*ចំពោះព្រួញដែលគេបាញ់ចេញពំពីធ្នូក្នុងសង្គ្រាម ដូច្នោះឯង*

*ព្រោះថា មនុស្សទ្រុស្តសីលមានច្រើននាក់ ។*

*កាលបើឫសឈើមិនមានអន្តរាយទេ*

*នៅមាំមួនល្អ ដូច្នេះ ទោះជាកាប់ដើមឈើនោះចោលក៏ដោយ*

*វារមែងដុះឡើងវិញទៀតបានមានឧបមា ដូចម្ដេចមិញ កាលបើតណ្ហា បុគ្គលមិនទាន់កម្ចាត់បានហើយ សេចក្ដីទុក្ខនេះឯង*

*ក៏តែងកើតរឿយៗ មានឧបមេយ្យ ដូច្នោះឯង ។*

*បុគ្គលដែលប្រាថ្នានឹងឆ្លងមហាសមុទ្រ*

*ប៉ុន្តែឡើងក្បូនឈើដ៏តូច ក៏រមែងលិចចុះទៅក្នុងមហាសមុទ្រ*

*យ៉ាងណាមិញ បុគ្គលដែលចិញ្ចឹមជីវិតដោយប្រពៃ*

*ប៉ុន្តែអាស្រ័យនឹងបុគ្គលខ្ជិលច្រអូស ក៏រមែងលិចចុះ*

*ក្នុងមហាសមុទ្រគឺវដ្តសង្សារ យ៉ាងនោះឯង ។*

# សីល សមាធិ និង បញ្ញា

ទាំងអម្បាលនោះ ដែលបុគ្គលណាបានអប់រំល្អហើយ

បុគ្គលនោះក៏រមែងបានឈានកន្លងនូវវិស័យនៃមារ

រមែងរុងរឿងដូចជាព្រះអាទិត្យ ។

*បើរកអ្នកប្រាជ្ញ*

*ដែលមានធម៌ជាគ្រឿងនៅដោយប្រពៃ*

*មានប្រាជ្ញាខ្ជាប់ខ្ជួនមកជាសម្លាញ់ ត្រាច់ទៅជាមួយគ្នាមិនបានទេ*

*បុគ្គលគប្បីត្រាច់ទៅម្នាក់ឯង ដូចជា*

*ព្រះរាជាលះបង់នូវដែនដែលមានភ័យ ដូច្នោះដែរ ។*

***ធម្មតាផែនដី រមែងអត់ទ្រាំចំពោះវត្ថុទាំងពួង***

***ទោះស្អាតក្តី អាក្រក់ក្តី ដែលគេដាក់ចុះហើយ***

***រមែងមិនធ្វើនូវសេចក្តីថ្នាំងថ្នាក់ចិត្ត និងត្រេកអរឡើយ***

***យ៉ាងណា អ្នកគួរអត់ទ្រាំនូវការរាប់អាន***

***និងការមើលងាយរបស់ជនទាំងនោះ ។***

*ធម្មតាទឹក រមែងផ្សព្វផ្សាយត្រជាក់ស្មើ*

*ចំពោះជនទាំងល្អ ទាំងអាក្រក់ រមែងកម្ចាត់បង់នូវធូលី*

*និងមន្ទិល យ៉ាងណា អ្នកចូរចម្រើននូវមេត្តាឱ្យស្មើ*

*ចំពោះមិត្ត និង សត្រូវ ក៏យ៉ាងនោះដែរ ។*

*ឆ្កែឃើញឆ្កែផងគ្នា រមែងញ្ញេញធ្មេញបង្ហាញគ្នា*

*ដើម្បីនឹងបៀតបៀនគ្នា មនុស្សទុរជន (មានចិត្តអាក្រក់)*

*ឃើញមនុស្សទុរជនដូចគ្នា ក៏រមែងប្រាថ្នានូវសេចក្តីបៀតបៀនគ្នា*

*ដែលកើតអំពីសេចក្តីក្រោធ ។*

*មិត្រណា ដែលគិតតែពីចង់បានទ្រព្យ*

*របស់មិត្រសម្លាញ់តែម្យ៉ាង មិត្រដែលមានសម្ដីល្អតែមាត់*

*និង ពូកែប៉ុននិយាយប្រចុបអែបអបចាក់បណ្ដោយតាមមិនឱ្យទាស់*

*មិត្រនោះ គឺជាមិត្រនាំឱ្យវិនាស ។*

*បុគ្គលកុំគប្បីមើលងាយនូវបុណ្យ*

*ថាបុណ្យបន្តិចបន្តួច នឹងមិនឱ្យផលឡើយ*

*សូម្បីក្អមទឹករមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ*

*អ្នកមានប្រាជ្ញា កាលដែលសន្សំនូវបុណ្យ*

*បន្តិចម្តងៗ ក៏គង់ពេញដោយបុណ្យបាន ។*

*ស្ទឹងទាំងឡាយ មិនដែលផឹកទឹកខ្លួនឯងឡើយ*

*ដើមឈើមិនដែលស៊ីផ្លែខ្លួនឯងឡើយ*

*ទឹកភ្លៀងដែលធ្លាក់ចុះមិនដែលស៊ីសំទូង ក្នុងកាលណាម្តងឡើយ*

*ទ្រព្យសម្បត្តិរបស់សប្បុរសទាំងឡាយ ក៏ប្រព្រឹត្តទៅ*

*ដើម្បីជាប្រយោជន៍ដល់អ្នកដទៃ ដូច្នោះដែរ ។*

## *ពិតមែន តាំងពីកាលណាមក*

## *ក្នុងលោកនេះ ពៀរទាំងឡាយមិនរម្ងាប់ដោយពៀរឡើយ*

## *ពៀរទាំងឡាយតែងរម្ងាប់ដោយមិនមានពៀរ*

## *នេះជាធម៌ចាស់មានយូរណាស់មកហើយ ។*

*ផ្ទះដែលប្រក់ខ្ញីខ្ញាហើយ*

*ដំណក់ទឹកភ្លៀងរមែងលេចរហូត*

*យ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំទុកល្អហើយ*

*រាគៈរមែងចាក់ដោត យ៉ាងនោះឯង ។*

***បុគ្គលអ្នកធ្វើបាប***

***តែងសោកស្ដាយក្នុងលោកទាំងពីរ***

***គឺសោកស្ដាយក្នុងលោកនេះ ១ និង ក្នុងលោកខាងមុខ ១***

***បុគ្គលនោះ រមែងសោកស្ដាយក្ដៅក្រហាយ***

***ព្រោះឃើញអំពើសៅហ្មងរបស់ខ្លួន ។***

*យសតែងចម្រើនកុះករ*

*ដល់បុគ្គលអ្នកមានសេចក្ដីប្រឹងប្រែង មានស្មារតី*

*មានការងារស្អាត (ឥតទោស) ជាអ្នកពិចារណា*

*រួចហើយទើបធ្វើ ជាអ្នកសង្រួម រស់នៅដោយធម៌*

*មិនមាននូវសេចក្ដីប្រមាទ ។*

ក្លិនផ្កាឈើ ផ្សាយទៅច្រាស់ខ្យល់មិនបាន

ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនខ្លឹមក្រស្នាក្តី ក្លិនផ្កាម្លិះរូតក្តី

ក៏ផ្សាយទៅច្រាស់ខ្យល់មិនបាន ចំណែកក្លិន

របស់សប្បុរស រមែងផ្សាយទៅច្រាស់ខ្យល់បាន

ព្រោះសប្បុរសរមែងផ្សាយទៅគ្រប់ទិស ។

*យប់យូរសម្រាប់អ្នកដែលដេកមិនលក់*

*យោជន៍ឆ្ងាយដាច់ស្រយាលសម្រាប់អ្នក*

*ដែលស្មើយកម្លាំងហើយ*

*វដ្តសង្សារ វែងឆ្ងាយសម្រាប់បុគ្គលពាលទាំងឡាយ*

*ដែលមិនដឹងច្បាស់នូវព្រះធម៌ ។*

*បុគ្គល កាលស្វះស្វែងរកកល្យាណមិត្ត*

*បើមិនបានមិត្តដ៏ប្រសើរជាងខ្លួន ឬមិត្តដែលស្មើ និងខ្លួនទេ*

*គប្បីប្រព្រឹត្តនៅតែម្នាក់ឯង ឱ្យខ្ជាប់ខ្ជួនវិញ ព្រោះថាសហាយតា*

*មិនមានក្នុងបុគ្គលពាលឡើយ ។*

*អ្នកណា ជាមនុស្សពាល*

*ហើយដឹងនូវភាពនៃខ្លួនថាជាពាល*

*អ្នកនោះនឹងទៅជាបណ្ឌិតខ្លះ ដោយហេតុដែលដឹងខ្លួនថា*

*ជាពាលនោះឯង អ្នកណាជាមនុស្សពាល មានសេចក្តីប្រកាន់ថា*

*ខ្លួនជាបណ្ឌិត អ្នកនោះឈ្មោះថា ជាមនុស្សពាលដោយពិត ។*

***ការចេះដឹង កើតឡើងដល់បុគ្គលពាល***

***គ្រាន់តែដើម្បីសេចក្តីវិនាសប៉ុណ្ណោះ***

***រមែងញុំាងក្បាលគឺបញ្ញាឱ្យធ្លាក់ចុះ បំផ្លិចបំផ្លាញ***

***ចំណែកនៃធម៌ស គឺកុសលរបស់បុគ្គលពាលនោះឯង ។***

**ជនពាលទាំងឡាយ**

**អាប់ប្រាជ្ញា មានខ្លួនបីដូចជាសត្រូវ**

**ដើរសាងបាបកម្ម**

**ដែលមានផលក្តៅក្រហាយ ។**

*ភ្នំថ្មតាន់ មិនរំភើបព្រោះខ្យល់*

*ដូចម្ដេចមិញ បណ្ឌិតទាំងឡាយ*

*ក៏មិនរំភើប ព្រោះពាក្យតិះដៀល*

*នឹងពាក្យសរសើរ ដូច្នោះឯង ។*

*អ្នកណាគប្បីឱ្យឱវាទ ទូន្មានប្រៀនប្រដៅ*

*និងហាមប្រាមចាកធម៌របស់សប្បុរស អ្នកនោះឯង*

*រមែងជាទីស្រឡាញ់របស់ពួកសប្បុរស*

*ប៉ុន្តែមិនជាទីស្រឡាញ់របស់ពួកអសប្បុរស ។*

***ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ***

***អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឱ្យត្រង់)***

***អ្នកចាំងឈើ តែងចាំងឈើ ឯបណ្ឌិតទាំងឡាយ***

***តែងទូន្មានខ្លួន ដូច្នោះដែរ ។***

***ជនទាំងឡាយណា ប្រព្រឹត្តតាមធម៌***

***ដែលតថាគតទ្រង់សម្ដែងហើយដោយប្រពៃ***

***ជនទាំងនោះនឹងឆ្លងនូវលំនៅនៃមច្ចុ***

***ដែលមិនងាយឆ្លងបាន ហើយដល់ព្រះនិព្វាន ។***

*បើវាចាសូម្បី ១,000 ម៉ាត់ ជាវាចា*

*ប្រកបដោយបទឥតប្រយោជន៍ វាចានោះពុំប្រសើរឡើយ*

*អ្នកណាស្ដាប់បទប្រយោជន៍ណាហើយ*

*រមែងស្ងប់រម្ងាប់បានបទប្រយោជន៍នោះ*

*សូម្បីតែ ១បទ ក៏ឈ្មោះថាប្រសើរជាង ។*

*ធម៌ ៤ ប្រការគឺ អាយុ១ វណ្ណៈ១ សុខៈ១ ពលៈ១*

*រមែងចម្រើនដល់អ្នកដែលមានសេចក្ដីឱនកាយថ្វាយបង្គំ*

*ជាប្រក្រតី មានសេចក្ដីកោតក្រែង ដល់បុគ្គល*

*ដែលចម្រើនជាងខ្លួន អស់កាលជានិច្ច ។*

*បុគ្គលរស់នៅ ១០០ ឆ្នាំ*

*ជាមនុស្សទ្រុស្តសីល មានចិត្តមិនបានតម្កល់ខ្ជាប់*

*ការរស់នៅតែ ១ថ្ងៃ របស់លោកដែលមានសីល*

*ជាប្រក្រតី ឈ្មោះថាប្រសើរជាង ។*

*បុគ្គលធ្វើបុណ្យ*

*គួរធ្វើបុណ្យនោះឱ្យរឿយៗ គួរធ្វើសេចក្តីពេញចិត្ត*

*ក្នុងបុណ្យនោះ ការសន្សំបុណ្យ*

*តែងនាំមកនូវសេចក្តីសុខមកឱ្យ ។*

*បុប្ផជាតិ ដែលមានពណ៌ស្រស់ល្អ*

*តែមិនមានក្លិនក្រអូប យ៉ាងណាមិញ*

*វាចាសុភាសិត ជាវាចាដែលមិនមានផល*

*ដល់បុគ្គលដែលមិនធ្វើតាម ក៏យ៉ាងនោះដែរ ។*

ចំណែកបុប្ផជាតិ ដែលមានពណ៌ស្រស់ល្អ

ព្រមទាំងមានក្លិនក្រអូបសាយ ដល់អ្នកប្រដាប់

យ៉ាងណាមិញ វាចាដែលជាសុភាសិត ជាវាចាមានប្រយោជន៍

អ្នកដែលបានធ្វើតាមដោយល្អ ក៏យ៉ាងនោះដែរ ។

***ផ្កាឈូកមានក្លិនក្រអូបឈ្ងុយឈ្ងប់ដុះឡើង***

***ក្នុងគំនរសំរាមដែលគេចាក់ចោលក្បែរផ្លូវធំ***

***ជាផ្កាដែលជាទីស្រឡាញ់ពេញចិត្ត***

***(ដល់អ្នកដំណើរ) យ៉ាងណាមិញ ។ (ត)***

*សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ*

*ទោះបីជានៅក្នុងសមាគមនៃ*

*ពួកជនដែលដូចជាកងសំរាមក៏ដោយ*

*ក៏នៅតែរុងរឿងលើសបុថុជ្ជនទាំងឡាយ*

*ដែលងងឹងសូន្យឈឹង ដោយបញ្ញាក៏យ៉ាងនោះដែរ ។*

*បុគ្គលធ្វើបាបកម្មហើយ*

*ទោះបីជាចូលទៅឰដ៏អាកាសក្តី*

*ក្នុងកណ្តាលសមុទ្រក្តី*

*កាន់ចន្លោះផ្ទះក្តី កាន់ចន្លោះភ្នំទាំងឡាយក្តី*

*ក៏មិនអាចរួចចាកបាបកម្មរបស់ខ្លួនបានឡើយ ។*

***សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា***

***និងតែងខ្លាចចំពោះសេចក្តីស្លាប់គ្រប់ៗរូប***

***បុគ្គលគួរធ្វើខ្លួនជាឧបមាហើយ មិនគួរប្រហារ***

***ដោយខ្លួនឯង មិនគួរប្រើគេឱ្យប្រហារឡើយ ។***

ជនណាស្វែងរកសេចក្ដីសុខដើម្បីខ្លួនឯង

តែបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្ដីសុខ

ដោយអាជ្ញា ជននោះលះលោកនេះទៅហើយ

នឹងមិនបានសេចក្ដីសុខឡើយ ។

*បុគ្គលកំណាញ់ស្វិតស្វាញ*

*មិនបានទៅកើតទេវលោកទេ*

*ជនពាលទាំងឡាយមិនសរសើរទានឡើយ*

*ចំណែកអ្នកប្រាជ្ញតែងអនុមោទនាទាន ព្រោះហេតុនោះ*

*លោកតែងបានសេចក្តីសុខក្នុងលោកខាងមុខ ។*

*ការត្រឡប់បានជាអត្តភាពជាមនុស្សបានដោយកម្រ*

*ការរស់នៅសត្វទាំងឡាយបានដោយកម្រ*

*ការស្ដាប់ធម៌របស់សប្បុរសបានដោយកម្រ*

*ការកើតឡើងនៃព្រះពុទ្ធទាំងឡាយបានដោយកម្រ ។*

ភ្លើងស្មើដោយរាគៈ មិនមាន

ទោសកំហុសស្មើដោយទោសៈ មិនមាន

ទុក្ខទាំងឡាយស្មើដោយខន្ធ មិនមាន

សុខក្រៅពីសេចក្តីស្ងប់ មិនមាន ។

*ច្រែះកើតអំពីដែក លុះកើតអំពីដែកនោះហើយ*

*រមែងស៊ីដែកនោះវិញ យ៉ាងណាមិញ*

*កម្មទាំងឡាយរបស់ខ្លួនតែងនាំបុគ្គលអ្នកប្រព្រឹត្ត*

*ឱ្យទៅកាន់ទុគ្គតិ ក៏យ៉ាងនោះឯង ។*

*មន្តទាំងឡាយមានការមិនស្វាធ្យាយន៍ ជាមន្ទិល*

*ផ្ទះទាំងឡាយមានការមិនថែទាំ ជាមន្ទិល*

*សេចក្តីខ្ជិល ជាមន្ទិលរបស់ពណ៌សម្បុរ*

*សេចក្តីប្រមាទ ជាមន្ទិលរបស់បុគ្គលអ្នករក្សា ។*

*ឥឡូវខ្លួនអ្នកដូចស្លឹកឈើទុំហើយ*

*ទាំងពួកបុរសរបស់យមរាជក៏ប្រាកដដល់អ្នកហើយ*

*ខ្លួនអ្នកតាំងនៅក្នុងមាត់នៃសេចក្តីវិនាស ស្បៀងក៏មិនមានសូម្បីតែស្បៀងគឺ*

*កុសលរបស់អ្នក ក៏មិនទាន់មាននៅឡើយ ។*

*ដរាបណាអំពើល្អ មិនទាន់ហុចផល*

*ដរាបនោះមនុស្សល្អឃើញអំពើល្អថាមិនល្អ*

*តែពេលណាអំពើល្អហុចផលឱ្យ ពេលនោះមនុស្សល្អ*

*ឃើញអំពើល្អថា ល្អពិតមែន ។*

*ការមិនមានរោគ ជាលាភយ៉ាងក្រៃលែង*

*សេចក្តីសន្តោសតាមមានតាមបាន ជាទ្រព្យដ៏ប្រសើរ*

*សេចក្តីស្និទ្ធស្នាលនឹងគ្នា ជាញាតិដ៏ប្រសើរ*

*ព្រះនិព្វាន ជាបរមសុខ ។*

***ធម្មតាបុគ្គលដែលមិនមានសេចក្ដីខ្មាសបាប***

***ក្លាហានដូចជាសត្វក្អែក មានប្រក្រតីកំចាត់គុណអ្នកដទៃ***

***ប្រព្រឹត្តដើម្បីយកមុខ មាត់ អួតវាយឫកពា***

***សៅហ្មងហើយ រស់នៅយ៉ាងស្រួល ។***

*បុគ្គលនៅកម្លោះមានកម្លាំង*

*តែមិនព្យាយាមនៅក្នុងពេលដែលត្រូវព្យាយាម*

*បានចូលដល់ ភាពជាអ្នកខ្ជិលច្រអូស*

*មានចិត្តត្រិះរិះធ្លាក់ចុះហើយ ខ្ជិលច្រអូស*

*នឹងមិនបានជួប្រទះនូវផ្លូវនៃបញ្ញាឡើយ ។*

*ចិត្តរបស់ជនទាំងឡាយណា ត្រេកអរហើយ*

*ក្នុងការមិនបៀតបៀនជានិច្ច ទាំងយប់ទាំងថ្ងៃ*

*ជនទាំងឡាយនោះ ឈ្មោះថាជាសាវ័ក*

*របស់ព្រះគោតម ភ្ញាក់រលឹកសព្វៗកាល ។*

*បុគ្គលដែលប្រមាទហើយសេពនូវភរិយា*

*របស់អ្នកដទៃ រមែងដល់នូវឋានៈ ៤ យ៉ាងគឺៈ*

*ទីមួយបានរបស់ដែលមិនមែនជាបុណ្យ*

*ទីពីរដេកមិនលក់តាមសេចក្ដីប្រាថ្នា*

*ទីបីការនិន្ទា និង ទីបួនធ្លាក់នរក ។*

***អ្នកទាំងឡាយចូរជាអ្នកត្រេកអរហើយ***

***ក្នុងសេចក្តីមិនប្រមាទចូរតាមរក្សាចិត្តរបស់ខ្លួន***

***ចូររើខ្លួនឱ្យរួចផុតចេញពីភក់***

***ដូចជាដំរីដែលជាប់ភក់ហើយ ខំប្រឹងរើខ្លួន***

***ឱ្យរួចផុតចេញពីអំពីភក់ យ៉ាងដូច្នោះឯង ។***

*សីលនាំសេចក្តីសុខមកឱ្យរហូតដល់ជរា*

*សទ្ធាតម្កល់ទុកបានល្អហើយ នាំសេចក្តីសុខមកឱ្យ*

*ការបាននូវបញ្ញា នាំសេចក្តីសុខមកឱ្យ*

*ការមិនធ្វើនូវអំពើបាបទាំងឡាយ នាំសេចក្តីសុខមកឱ្យ ។*

*ភោគទាំងឡាយ តែងសម្លាប់នូវអ្នកដែលល្ងង់ខ្លៅ*

*តែមិនសម្លាប់នូវអ្នកដែលស្វែងរកត្រើយគឺព្រះនិព្វាន*

*អ្នកអាប់ឥតបញ្ញារមែងសម្លាប់ខ្លួនឯង*

*ដូចជាសម្លាប់អ្នកដទៃ ព្រោះប្រាថ្នាចង់បានភោគៈ ។*

*ស្រែទាំងឡាយមានស្មៅជាទោស*

*ពួកសត្វនេះក៏ជារាគៈជាទោស ព្រោះហេតុនោះហើយ*

*ទានដែលគេបានឱ្យហើយក្នុងបុគ្គល*

*ដែលប្រាសចាករាគៈ ជាទានមានផលច្រើន ។*

ព្រះអាទិត្យរុងរឿងបានតែក្នុងពេលថ្ងៃ

ព្រះចន្ទភ្លឺស្វាងរុងរឿងបានតែក្នុងពេលយប់

ព្រះមហាក្សត្រលុះតែទ្រង់គ្រឿងប្រដាប់សម្រាប់រាជ្យ ទើបរុងរឿងបាន

ព្រាហ្មណ៍ លុះត្រាតែចម្រើនឈាន ទើបរុងរឿងបាន

ឯព្រះពុទ្ធទ្រង់រុងរឿងបានដោយតេជៈទាំងថ្ងៃទាំងយប់ ។

*បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថា*

*ដូចជាឆ្នាំង គប្បីបិទនូវចិត្តនេះឱ្យដូចជាបិទទ្វារនគរ*

*គប្បីច្បាំងនូវមារ ដោយអាវុធ គឺបញ្ញា*

*គប្បីរក្សាទុកនូវធម៌ដែលខ្លួនឈ្នះហើយ ។*

*មច្ចុ គឺសេចក្តីស្លាប់ តែងកៀរយកទៅនូវនរជន*

*អ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ*

*កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ នុ៎ះឯង ដូចជាទឹកជំនន់ធំ*

*ដែលគួចយកអ្នកស្រុកកំពុងតែដេកលក់ទៅ ដូច្នោះឯង ។*

*ភមរជាតិ មិនធ្វើផ្កាឈើដែលមានពណ៌*

*និងក្លិនឱ្យវិនាសទេ ក្រេបយកតែរសហើរទៅ*

*យ៉ាងណាមិញ អ្នកប្រាជ្ញ*

*គប្បីត្រាច់ទៅក្នុងស្រុក ក៏យ៉ាងនោះដែរ ។*

***ផ្កាឈើមានទ្រង់ទ្រាយល្អ មានពណ៌ល្អ***

***តែគ្មានក្លិនក្រអូបរមែងមិនក្រអូបដល់អ្នកដែលទ្រទ្រង់***

***ដូចម្តេចមិញ វាចាសុភាសិត រមែងគ្មានផល***

***ដល់អ្នកដែលមិនធ្វើតាមដូច្នោះ ។***

*ផ្កាឈើមានទ្រង់ទ្រាយល្អ មានពណ៌ល្អ*

*រមែងក្រអូបដល់អ្នកដែលទ្រទ្រង់*

*ដូចម្ដេចមិញ វាចាសុភាសិត រមែងមានផល*

*ដល់អ្នកដែលធ្វើតាមដោយគោរព ។*

***មាលាការ ចេះធ្វើសំណុំនៃកម្រងផ្កា***

***អំពីគំនរនៃផ្កាផ្សេងៗគ្នា ឱ្យច្រើនបាន***

***យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ***

***គួរធ្វើឱ្យច្រើនយ៉ាងនោះ ។***

*សេចក្ដីស្រេកឃ្លាន ជារោគយ៉ាងក្រៃលែង*

*សង្ខារ ជាទុក្ខយ៉ាងក្រៃលែង អ្នកប្រាជ្ញ ដឹងច្បាស់*

*សេចក្ដីនុ៎ះ តាមពិតហើយ រមែងធ្វើឱ្យច្បាស់*

*នូវព្រះនិព្វានជាសុខក្រៃលែង ។*

*បុគ្គលណា ឃាត់សេចក្តីក្រោធ*

*ដែលកើតឡើងហើយ ដូចសារថីទប់រថ*

*កំពុងលឿនបាន តថាគត ហៅបុគ្គលនោះថា សារថី*

*ជនក្រៅពីនេះ គ្រាន់តែជាអ្នកកាន់ខ្សែបរ*

*មិនមែនសារថីឡើយ ( អ្នកបររថ ឬបង្ហាត់សេះ )។*

***ជនណា សម្លាប់សត្វផង និយាយកុហកផង***

***កាន់យកវត្ថុដែលគេមិនបានឱ្យផង សេពប្រពន្ធរបស់គេផង***

***ផឹកទឹកសុរា និងមេរ័យផង ជននោះឯងឈ្មោះថា***

***គាស់រំលើងឫសគល់របស់ខ្លួន ក្នុងលោកនេះដោយពិត ។***

***បើបុរសស្ត្រីធ្វើបុណ្យ***

***គប្បីធ្វើបុណ្យនោះឱ្យបានរឿយៗ***

***និងគប្បីធ្វើសេចក្តីពេញចិត្តក្នុងបុណ្យនោះផង***

***ព្រោះថាការសន្សំបុណ្យ នាំមកនូវសេចក្តីសុខ ។***

*ពាក្យចាក់ដោតរបស់អ្នកដទៃ*

*បុគ្គលមិនគួរធ្វើទុកក្នុងចិត្តទេ*

*កិច្ចដែលធ្វើហើយ និងមិនទាន់ធ្វើហើយរបស់ជនដទៃ*

*បុគ្គលមិនគួរពិនិត្យមើលទេ បុគ្គលគួរពិនិត្យតែកិច្ចទាំងឡាយ*

*ដែលធ្វើហើយ និងមិនទាន់ធ្វើហើយ របស់ខ្លួនតែម្យ៉ាង ។*

***លោកិយ៍មហាជននេះ ងងឹតណាស់***

***ដូចជាមនុស្សខ្វាក់ក្នុងលោក មានមនុស្សតិចនាក់ណាស់***

***ដែលបានដឹងច្បាស់នូវបញ្ញក្ខន្ធ តាមពិតតិចនាក់ណាស់***

***ដែលបានទៅកាន់ស្ថានសួគ៌ ដូចបក្សីដែលជាប់សំណាញ់***

***របស់ព្រានហើយ តិចណាស់ដែលបានរួចអំពីសំណាញ់បាន ។***

***បណ្ឌិតដឹងខ្លួនថា***

***ខ្លួនជាទីស្រឡាញ់របស់ខ្លួន***

***គួររក្សាខ្លួននោះឱ្យល្អ គួរស្ងួនគ្រងខ្លួនទុក***

***ក្នុងវ័យទាំងបី វ័យណាមួយ ។***

***បុគ្គលគួរចៀសបាបទាំងឡាយ***

***ឱ្យដូចនាយពាណិជ ដែលមានទ្រព្យច្រើន***

***តែមានគ្នាតិចចៀសវាងផ្លូវគួរខ្លាច ឬដូចជាបុរស***

***ប្រាថ្នាការរស់នៅចៀសវាងថ្នាំពិស ដូច្នោះដែរ ។***

*រូបនេះគ្រាំគ្រាអស់ហើយ*

*ជាទីសំណាក់នៃរោគ ជារបស់ពុកផុយ*

*រាងកាយនេះជារបស់ស្អុយ (នេះ) តែងបែកធ្លាយទៅវិញ*

*ព្រោះថាជីវិត មានសេចក្ដីស្លាប់ជាទីបំផុត ។*

*រាជរថទាំងឡាយ ដ៏វិចិត្ររមែងគ្រាំគ្រា*

*សូម្បីសរិរៈ ក៏ដល់នូវសេចក្តីគ្រាំគ្រាដូចគ្នា*

*ចំណែកធម៌របស់សប្បុរសទាំងឡាយ*

*រមែងមិនដល់នូវសេចក្តីគ្រាំគ្រា ដូច្នោះទេ ។*

***តថាគត ប្រាប់អ្នកទាំងឡាយឱ្យបានដឹង***

***សង្ខារទាំងឡាយ មានសេចក្តីសាបសូន្យជាធម្មតា***

***អ្នកទាំងឡាយ ចូរញ៉ាំងកិច្ចការទាំងពួងឱ្យសម្រេច***

***ដោយសេចក្តីមិនប្រមាទចុះ ។***

*អ្នកប្រាជ្ញ គប្បីសាងកោះ គឺអរហន្តផល*

*ជាកោះដែលជំនន់ គឺកិលេស ជន់ពន្លិចមិនបាន*

*ដោយសេចក្តីប្រឹងប្រែងផង ដោយសេចក្តីមិនប្រមាទផង*

*ដោយការសង្រួមក្នុងចតុប្បារិសុទ្ធសីលផង*

*ដោយការទូន្មានឥន្ទ្រិយផង ។*

***បណ្ឌិតមានប្រាជ្ញាមោះមុត កាលពួកបុគ្គលពាល***

***កំពុងប្រមាទ លោកមិនប្រមាទ កាលពួកបុគ្គលពាលកំពុងដេកលក់***

***លោកភ្ញាក់រឭកច្រើន លោករមែងលះបង់ចោលនូវ***

***បុគ្គលបែបនោះ ដូចសេះលឿន ដែលទៅចោល***

***សេះមានកម្លាំងទន់ទាប ដូច្នោះឯង ។***

*បណ្ឌិត ដែលមានសេចក្តី*

*ឆ្អែតក្នុងធម៌ មានចិត្តជ្រះថ្លាហើយ*

*រមែងដេកជាសុខ រមែងត្រេកអរក្នុងធម៌*

*ដែលព្រះអរិយៈ ប្រកាសទុកហើយគ្រប់ពេល ។*

បណ្តាលមនុស្សទាំងឡាយ

ពួកជនណាដែលឆ្លងដល់ត្រើយ គឺព្រះនិព្វាន

ពួកជននោះមានប្រមាណតិច ចំណែក

ពួកជនសត្វក្រៅនេះ រមែងស្ទុះទៅកាន់

ត្រើយ គឺ សក្កាយទិដ្ឋិ ។

***បណ្ឌិត គួរលះបង់ធម៌ខ្មៅចេញ***

***ញ៉ាំងធម៌ស ឱ្យចម្រើនឡើយ ដោយវិធីចេញចាក***

***អាល័យ គឺកាមគុណ ហើយឈមទៅរកព្រះនិព្វាន***

***ជាធម្មជាតមិនមានអាល័យ ។***

***ភិក្ខុមានចិត្តដូចផែនដី មិនក្រោធ***

***មានវត្តល្អ មានចិត្តនឹងធឹងដូចសសរគោល***

***មានចិត្តថ្លាដូចអន្លង់ប្រាសចាកភក់***

***សង្សារទាំងឡាយ របស់ភិក្ខុបែបនោះ រមែងមិនមាន ។***

*កាលបើលោកសន្និវាស*

*ត្រូវភ្លើងមានរាគៈជាដើម ឆេះទ្រលោមជានិច្ច*

*ម្ដេចក៏សើច ម្ដេចក៏ត្រេកត្រអាល*

*អ្នកទាំងឡាយត្រូវងងឹត គឺអវិជ្ជា រួបរឹតហើយ*

*ម្ដេចឡើយ ក៏មិនស្វែងរកប្រទីបគឺ ប្រាជ្ញា ។*

***អ្នកប្រាជ្ញទាំងឡាយ***

***ជាអ្នកខ្វល់ខ្វាយក្នុងឈាន ត្រេកអរក្នុងនេក្ខម្មៈ(បួស)***

***ជាឋានស្ងប់រម្ងាប់កិលេស សូម្បីទេវតា***

***និង មនុស្សទាំងឡាយនោះដែលជាអ្នក***

***ត្រាស់ដឹងខ្លួនឯង ទាំងមានស្មារតី ។***

*ខន្តី គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម*

*ព្រះពុទ្ធទាំងឡាយតែងពោលថា ព្រះនិព្វាន*

*ជាធម្មជាតដ៏ឧត្តម បុគ្គលដែលសម្លាប់សត្វដទៃ*

*មិនឈ្មោះថា បព្វជិតទេ បុគ្គលដែលបៀតបៀនសត្វដទៃ*

*ក៏មិនឈ្មោះថា សមណៈ ឡើយ ។*

*ការជួបប្រទះព្រះអរិយបុគ្គលទាំងឡាយ*

*ជាការល្អ និង ការនៅរួមជាមួយ*

*ជាហេតុឱ្យកើតសេចក្តីសុខសព្វកាល*

*បុគ្គលគប្បីមានសេចក្តីសុខអស់កាលជានិច្ចបាន*

*ព្រោះមិនបានជួបប្រទះបុគ្គលពាលទាំងឡាយ ។*

***ឥឡូវនេះ ខ្លួនអ្នកត្រូវជរាចូលមកដល់ហើយ***

***ជាអ្នករៀបចំដំណើរទៅកាន់សេចក្តីស្លាប់ មួយទៀត***

***ទីសំចតក្នុងចន្លោះ មិនមានដល់អ្នកទេ***

***ស្បៀង ក៏មិនមានដល់អ្នក ។***

*ស្នាមជើងក្នុងអាកាស មិនមាន*

*សមណៈខាងក្រៅ មិនមាន*

*សង្ខារទាំងឡាយជារបស់ទៀង មិនមាន*

*ព្រះពុទ្ធទាំងឡាយ មិនមានកិលេសជាគ្រឿងញាប់ញ័រទេ ។*

*បុគ្គលមិនបានឈ្មោះថាជា សមណៈ*

*ដោយភាពជាអ្នកមានក្បាលត្រងោលទេ*

*បុគ្គលមិនមានសីលវត្ត និង ធុតង្គវត្ត*

*ពោលតែពាក្យឡេះឡោះ ប្រកបដោយសេចក្តីប្រាថ្នា*

*និង លាភឈ្មោះថាជា សមណៈ ដូចម្តេចបាន ។ (ត)*

*លុះត្រាតែបុគ្គលណា រម្ងាប់បាបទាំងឡាយ*

*ទាំងតូច ទាំងធំ ដោយប្រការទាំងពួងបាន*

*ទើបហៅថា សមណៈ ព្រោះបាបទាំងឡាយ*

*ដែលបុគ្គលនោះរម្ងាប់បានហើយ ។*

*សតិ របស់ជនពួកណា ដែលឋិតនៅក្នុង កាយ*

*(កាយគតាសតិ) អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់*

*ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម*

*រមែងភ្ញាក់រឮក១ ដោយប្រពៃសព្វកាល ។*

*ពួកជនច្រើននាក់ ដែលមាន ក ព័ន្ធព័ទ្ធដោយ*

*សំពត់កាសាវៈ តែ (ប្រព្រឹត្ត) ធម៌ដ៏លាមក មិនសង្រួម*

*ពួកជនលាមកទាំងនោះ រមែងទៅកើតក្នុងនរក*

*ដោយសារកម្មទាំងឡាយដ៏លាមក ។*

*បព្វជិតទ្រុស្តសីល*

*ស៊ូវបរិភោគដុំដែកដែលកំពុងក្តៅ*

*មានពណ៌អណ្តាតភ្លើងប្រសើរជាង*

*បព្វជិតទ្រុស្តសីល មិនសង្រួម បរិភោគដុំបាយ*

*អ្នកដែននឹងប្រសើរដូចម្តេចបាន ។*

***ស្បូវភ្លាំង ដែលបុគ្គលកាន់មិនចំណាប់***

***រមែងលះដៃ យ៉ាងណាមិញ ភាពជាសមណៈ***

***ដែលបព្វជិតមិនស៊ប់សួនហើយ***

***រមែងទាញបព្វជិតនោះ ទៅនរកយ៉ាងនោះឯង ។***

*សត្វទាំងឡាយ ដែលប្រកាន់មិច្ឆាទិដ្ឋិ*

*រមែងយល់ឃើញក្នុងហេតុដែលឥតទោស*

*ថាជាហេតុមានទោស យល់ឃើញក្នុងហេតុដែល*

*មានទោសថា ជាហេតុឥតទោសផង*

*សត្វទាំងនោះតែងទៅកាន់ទុគ្គតិ ។*

*បុគ្គលមិនមានប្រាជ្ញា*

*កាលធ្វើអំពើអាក្រក់ រមែងមិនភ្ញាក់ខ្លួន*

*លុះកាលជាខាងក្រោយ ទើបក្តៅក្រហាយ*

*ដោយសារកម្មរបស់ខ្លួន ដូចត្រូវភ្លើងឆេះ ។*

*ភាពជាអ្នកមានសម្បុរផ្ទរផង់*

*មានសំឡេងពីរោះ ទ្រង់ទ្រាយល្អ រូបល្អ*

*ជាអធិបតី មានយសបរិវារ ផលទាំងអស់*

*រមែងបានដោយកំណប់ទ្រព្យ គឺ បុណ្យនុ៎ះ ។*

***បុគ្គលណា ទោះភិក្ខុក្តី ភិក្ខុនីក្តី***

***ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌គួរដល់ធម៌***

***ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តិតាមធម៌ បុគ្គលនោះ***

***ឈ្មោះថា ធ្វើសក្ការៈគោរពរាប់អាន***

***បូជា តថគត ដោយគ្រឿងបូជាដ៏ឧត្តម ។***

*ជនណា ដាំច្បារឈើមានផ្លែផ្កា ដាំដើមឈើមានម្លប់*

*សាងស្ពាន សាងរោង ឱ្យទានទឹកជីកស្រះ ឱ្យទីសំណាក់អាស្រ័យ*

*បុណ្យរមែងចម្រើនមិនដាច់ ទាំងថ្ងៃទាំងយប់ គ្រប់ពេលវេលា*

*ដល់ជនទាំងនោះ ជនទាំងនោះឈ្មោះថាជាអ្នកតាំងនៅក្នុងធម៌*

*ឈ្មោះថា បរិបូរណ៍សីល គួរទៅកាន់ឋានសួគ៌បាន ។*

*ទង់ ជាគ្រឿងប្រាកដរបស់រថ*

*ផ្សែង ជាគ្រឿងប្រាកដរបស់ភ្លើង*

*ព្រះរាជា ជាគ្រឿងប្រាកដរបស់ដែន*

*ភស្តា (ស្វាមី) ជាគ្រឿងប្រាកដរបស់ស្ត្រី*

*ម្នាលភិក្ខុទាំងឡាយ*

*បើពួកសត្វដឹងផលនៃការចែកទាន ដូចជាតថាគតដឹងដូច្នោះ*

*បើមិនទាន់ឱ្យទានទេ ក៏មិនហ៊ានបរិភោគឡើយ*

*មួយទៀត មន្ទិលគឺសេចក្តីកំណាញ់របស់សត្វទាំងនោះ*

*ក៏មិនគ្របសង្កត់ចិត្តបានឡើយ ។*

*មាតាបិតា ជាព្រះព្រហ្មផង ជាបុព្វាចារ្យផង*

*ជាបុព្វទេវាផង ជាហុនេយ្យផង របស់កូនទាំងឡាយ*

*ហេតុនេះកូនទាំងឡាយ គួរធ្វើសក្ការៈដល់មាតាបិតា*

*ដោយបច្ច័យទាំង ៤ មាន បាយទឹក សំពត់ ទីស្នាក់នៅ*

*ថ្នាំពេទ្យជាដើម  បុគ្គលអ្នកធ្វើនោះ នឹងបានទៅឋានសួគ៌ ។*

*ជីវិតជាទីស្រឡាញ់ ជាទីហួងហែងដ៏ក្រៃលែង*

*នៃសត្វទាំងឡាយ គ្រប់ជីវិតប្រាថ្នាសុខ ប្រាថ្នារស់នៅជាមួយនឹង*

*បុគ្គលជាទីស្រឡាញ់ ជាមួយនឹងទ្រព្យសម្បត្តិ និងសេចក្ដីប្រសើរ*

*គ្រប់យ៉ាង បុគ្គលគួរមានខ្លួនឯងជាគ្រឿងប្រៀបធៀប*

*គួរអប់រំមេត្តាចិត្ត ។*

***វ័យរបស់តថាគតចាស់ហើយ***

***ជីវិតរបស់តថាគត មានប្រមាណតិច***

***តថាគតនឹងលះបង់អ្នកទាំងឡាយ ហើយទៅ***

***ឯទីពឹងចំពោះខ្លួន តថាគត បានធ្វើទុកហើយ ។***

*ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ*

*ឥឡូវតថាគតប្រាប់អ្នកទាំងឡាយឱ្យបានដឹងថា*

*សង្ខារទាំងឡាយ មានសេចក្តីសាបសូន្យជាធម្មតា*

*អ្នកទាំងឡាយចូរញុំាងកិច្ចទាំងពួងឱ្យសម្រេច*

*ដោយសេចក្តីមិនប្រមាទចុះ ។*

***គ្រឿងការពារទាំងឡាយ***

***រមែងមិនមានដល់បុគ្គលអ្នកស្លាប់ទេ***

***មានតែពួកញាតិមិត្រ ឬ ពួកសម្លាញ់ជាទាយាទ***

***នាំយកទ្រព្យរបស់បុគ្គលស្លាប់នោះទៅ ។***

*បុគ្គលមិនបានអាយុវែង ព្រោះទ្រព្យទេ*

*ទាំងមិនមែនលះបង់ជរាបាន ព្រោះទ្រព្យដែរ*

*អ្នកប្រាជ្ញពោលថា ជីវិតនេះ តិចពេកណាស់*

*មិនទៀងទាត់ មានសភាពប្រែប្រួលជាធម្មតា ។*

*ជីវិតគឺអាយុមានប្រមាណតិច*

*ដែលជរាបញ្ជូនតៗគ្នា ទីពឹងទាំងឡាយ*

*មិនមានដល់បុគ្គលដែលត្រូវជរាបញ្ជូនតៗគ្នាទៅទេ*

*កាលបើបុគ្គលឃើញភ័យក្នុងមរណៈនុ៎ះ គួរធ្វើបុណ្យទាំងឡាយ*

*ដែលជាហេតុនាំមកនូវសេចក្តីសុខ ។*

*សត្វត្រដេវវិច រក្សានូវស៊ុតវាយ៉ាងណា សត្វចាមរីរក្សានូវកន្ទុយវាយ៉ាងណា មាតារក្សាកូនប្រុសតែមួយយ៉ាងណា ជនមានភ្នែកតែម្ខាងរក្សាភ្នែកយ៉ាងណាមិញ អ្នកទាំងឡាយ ចូរជាអ្នកមានសីលឱ្យជាទីស្រឡាញ់ ជាទីប្រកបដោយសេចក្តីគោរពក្នុងសីល ចូរតាមរក្សាសីលឱ្យបានសព្វកាល ក៏យ៉ាងនោះដែរ ។*

*សត្វទាំងឡាយបានទៅកាន់ឋានសួគ៌ ក៏ព្រោះសីល*

*បានភោគៈ ក៏ព្រោះសីល បានទៅកាន់ទីរំលត់ទុក្ខគឺនិព្វាន*

*ក៏ព្រោះសីល ព្រោះហេតុដូច្នោះហើយ សាធុជនទាំងឡាយ*

*គប្បីជម្រះសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មងឡើយ ។*

# ឈូកដែលដុះឡើង

ចម្រើនក្នុងទឹក មានក្លិនល្អជាទីត្រេកអរនៃចិត្ត

មិនជាប់ដោយទឹក ដូចម្ដេចមិញ ព្រះពុទ្ធទ្រង់កើតឡើងក្នុងលោក

ក៏មិនជាប់ដោយលោកឡើយ ដូចផ្កាឈូក

មិនជាប់ដោយទឹកដូច្នោះដែរ ។

*គ្រហស្ថ អ្នកបរិភោគកាម ខ្ជិលច្រអូស មិនល្អ*

*អ្នកបួស មិនសង្រួម មិនល្អ*

*ព្រះរាជា អ្នកមិនពិចារណាហើយធ្វើ មិនល្អ*

*បណ្ឌិត ដែលច្រើនដោយក្រោធ ការក្រោធនោះមិនល្អ ។*

*ព្រៃ ជាដំណើររបស់ពួកម្រឹគ*

*អាកាស ជាដំណើររបស់ពួកបក្សី*

*សេចក្ដីវិនាស ជាដំណើររបស់សង្ខតធម៌ទាំងឡាយ*

*ព្រះនិព្វាន ជាដំណើររបស់ព្រះអរហន្ត ។*

***បុណ្យរមែងចម្រើនដល់អ្នកឱ្យទាន***

***វេរាមិនចម្រើនដល់បុគ្គលដែលអ្នកសង្រួម បុគ្គលអ្នកឈ្លាស***

***(បរិបូណ៌ដោយញាណ) រមែងលះបង់នូវអំពើលាមកបាន***

***បុគ្គលនោះក៏បរិនិព្វាន ព្រោះអស់ រាគៈ ទោសៈ មោហៈ ។***

***ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី***

***ដែលតថាគតសម្តែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ***

***លុះអំណើះតអំពីតថាគតទៅ ធម៌ និង វិន័យនោះ***

***ជាគ្រូរបស់អ្នកទាំងឡាយ ។***

# *ជីវិតរបស់សត្វលោកតិចតួចណាស់*

*ត្បិតជរា តែងនាំចូលទៅរកសេចក្តីស្លាប់ កាលបើសត្វដែលត្រូវជរា*

*នាំចូលទៅជិតសេចក្តីស្លាប់ហើយ នឹងរកអ្វីជ្រកកោនពុំមានឡើយ*

*កាលបើបុគ្គលសម្លឹងឃើញភ័យនុ៎ះ ក្នុងសេចក្តីស្លាប់ហើយ*

*ជាអ្នកប្រាថ្នាសេចក្តីស្ងប់ ត្រូវលះបង់អាមិសៈក្នុងលោកចេញ ។*

*ភិក្ខុណា នៅកម្លោះ*

*ព្យាយាមខ្នះខ្នែង នៅក្នុងព្រះពុទ្ធសាសនា*

*ភិក្ខុនោះ នឹងញ៉ាំងលោកនេះ*

*ឱ្យភ្លឺស្វាងបាន ដូចជាព្រះចន្ទរះផុតពពក*

*ភ្លឺត្រចះត្រចង់ យ៉ាងនោះឯង ។*

*បុគ្គលឱ្យបាយ ឈ្មោះថាឱ្យកម្លាំង ឱ្យសំពត់*

*ឈ្មោះថាឱ្យពណ៌សម្បុរ ឱ្យយានជំនិះ ឈ្មោះថាឱ្យសេចក្ដីសុខ*

*ឱ្យប្រទីប ឈ្មោះថាឱ្យចក្ខុ   មួយទៀតបុគ្គលណា ឱ្យទីអាស្រ័យ*

*បុគ្គលនោះឈ្មោះថា ឱ្យវត្ថុគ្រប់យ៉ាង បុគ្គលណាប្រៀនប្រដៅធម៌*

*បុគ្គលនោះឈ្មោះថា ឱ្យព្រះនិព្វាន ។*

# សេចក្តីសុខចម្រើន ៣៨ ប្រការ

*កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ១*

*កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១*

*កិរិយាបូជាដល់បុគ្គលគួរបូជាទាំងឡាយ ១*

*ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។*

*កិរិយានៅក្នុងប្រទេសដ៏សមគួរ ១*

*ភារៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ១*

*កិរិយាតម្កល់ខ្លួនដោយប្រពៃ ១*

*ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។*

*ភារៈនៃបុគ្គលបានស្តាប់បានរៀនហើយដោយច្រើន ១*

*សិល្បសាស្ត្រគឺសេចក្តីឆ្លៀវឆ្លាតក្នុងហត្ថកម្ម ១*

*វិន័យដែលបុគ្គលសិក្សាដោយប្រពៃ ១*

*វាចាដែលបុគ្គលពោលត្រឹមត្រូវ ១*

*ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។*

*កិរិយាបម្រើនូវមាតា ១*

*កិរិយាបម្រើនូវបិតា ១*

*សេចក្តីសង្គ្រោះដល់បុត្រ និង ភរិយា ១*

*ការងារទាំងឡាយដែលមិនច្របូកច្របល់ ១*

*ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។*

*កិរិយាបរិច្ចាគទាន ១*

*កិរិយាប្រព្រឹត្តនូវធម៌ (កុសលកម្មបទ១០) ១*

*សេចក្តីសង្គ្រោះដល់ញាតិទាំងឡាយ ១*

*ការងារទាំងឡាយដែលមិនមានទោស ១*

*ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។*

*កិរិយាមិនត្រេកអរក្នុងបាប និង កិរិយាវៀរចាកបាប ១*

*សេចក្តីសង្រួមវៀរចាកផឹកនូវទឹកស្រវឹង ១*

*សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ ១*

*ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។*

*សេចក្តីគោរពដល់បុគ្គលដែលគួរគោរព ១*

*កិរិយាប្រព្រឹត្តបន្ទាបខ្លួនឱ្យទន់ភ្លន់ ១*

*សេចក្តីសន្តោសចំពោះវត្ថុតាមមានតាមបាន ១*

*កតញ្ញុតា ការដឹងនូវគុណដែលបានធ្វើហើយ ១*

*កិរិយាស្តាប់នូវធម៌តាមកាល ១ ទាំង ៥ នេះជាមង្គលដ៏ឧត្តម ។*

*សេចក្តីអត់ធន់ (ខន្តី) ១*

*ភាវៈនៃបុគ្គលដែលប្រដៅបានដោយងាយ ១*

*កិរិយាបានឃើញបានជួបនូវសមណៈ ១*

*កិរិយាសន្ទនានូវធម៌តាមកាលពេលវេលា ១*

*ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។*

*កិរិយាព្យាយាមដុតនូវបាបធម៌ក្នុងសន្តាន ១*

*កិរិយាប្រព្រឹត្តនូវព្រហ្មចរិយធម៌ ១*

*កិរិយាឃើញនូវអរិយសច្ចធម៌ទាំងឡាយ ១*

*កិរិយាជាក់ច្បាស់នូវព្រះនិព្វាន ( អរហត្តផល ) ១*

*ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។*

*ចិត្តដែលលោកធម៌ពាល់ត្រូវហើយមិនកម្រើកញាប់ញ័រ ១*

*មិនមានសេចក្ដីសោកសៅ ១*

*ប្រាសចាកនូវកិលេសទាំងពួង ១*

*សភាពនៃចិត្តដែលក្សេមក្សាន្ត ១*

*ទាំង ៤ នេះជាមង្គលដ៏ឧត្ដម*

# *ឯកសារយោង*

*-ព្រះពុទ្ធភាសិត ៤៣ គាថា ប៊ុត សាវង្ស ព.ស. ២៥៤៥*

*-ឧបមាភាសិត ៤៩ ប៊ុត សាវង្ស ព.ស. ២៥៥១*

*-១០០ គាថា ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥១៣*

*-ជំនួយសតិ អគ្គបណ្ឌិត ប៊ុត សាវង្ស*

-ធម្មបទ ២៣ គាថា ពុទ្ធិកបណ្ឌិតសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្រ្តកម្ពុជា ព.ស. ២៥៦៣

-អធិប្បាយគាថាធម្មបទ បណ្ឌិតមហា ឈឹម ស៊ុម ព.ស. ២៤៥៤

-ព្រះគាថានិងព្រះសូត្រ ភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ ព.ស. ២៥៥៦

-ធម្មបទគាថា ភិក្ខុ ធិន ភេន ឥន្ទប្បញ្ញោ ព.ស. ២៥៥៦

*-សិក្សាព្រះគាថា ភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ ព.ស. ២៥៥៤*

*-ហេសប៊ុកផេក ពន្លឺនៃព្រះធម៌*

*-ធម្មបទគាថា ព្រហ្ម មេត្តា គតិបណ្ឌិតោ ព.ស. ២៥៦២*

*-សង្គហគាថា អគ្គទត្តោ គល់ សុភាព ព.ស. ២៥៥៨*

*-ប្រជុំធម៌ថ្វាយបង្គំព្រះ ព្រះគ្រូសិរីវិសុទ្ធិញាណ នឿន ឈិនឡុង ព.ស. ២៥៦៧*

MP
Publishing House

រោងពុម្ព អិមភី
MP Publishing House

Telegram
រោងពុម្ព អិមភី
@ phonmao@yahoo.com

Tel: 012 990 524 I 081 777 800 I 088 8888 908


អ្វីដែលត្រូវលះបង់ គឺបាប
អ្វីដែលត្រូវសម្អាត គឺចិត្ត
អ្វីដែលត្រូវប្រព្រឹត្ត គឺបុណ្យ
ភិក្ខុ សិរីសាក្យមុនីបុត្តោ